# ប្រាសាទអាស្រមមហាឥសី

អ្នកប្រាជ្ញ និងអ្នកស្រាវជ្រាវអំពីអាស៊ីអាគ្នេយ៍មួយចំនួនយល់ស្របគ្នាថាអង្គរបុរីជារាជធានីរបស់អាណាចក្រហ្វូណន។ នៅស្ថានីយអង្គរបុរី ពុំមានសេសសល់សំណង់ស្ថាបត្យកម្មច្រើននោះទេ ពោលភាគច្រើននៅសល់តែគ្រឹះប្រាសាទចាស់ៗប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏មានប្រាសាទចំនួនពីរដែលនៅរូបរាងល្អប្រសើរ ពោលគឺប្រាសាទភ្នំដា និងប្រាសាទអាស្រមមហាឥសី។ ក្រៅពីនេះក៏មានសិល្បៈលុងភ្នំមួយចំនួននៅចង្កេះភ្នំ ដែលជាប្រភេទសំណង់ស្ថាបត្យកម្មដំបូងនៅស្រុកខ្មែរដែលមានឥទ្ធិពលពីឥណ្ឌា។

ប្រាសាទភ្នំដា មានទីតាំងស្ថិតនៅភូមិព្រៃកតាផូ ឃុំគោកធ្វក ស្រុកអង្គរបុរី ខេត្តតាកែវ មានចម្ងាយប្រមាណ ១០០គ.ម.ពីរាជធានីភ្នំពេញ។ យើងអាចធ្វើដំណើរទៅប្រាសាទនេះតាមរយៈផ្លូវគោកក៏បាន និងផ្លូវទឹកក៏បាន (ព្រែកជីកពីទីរួមខេត្តតាកែវមកកាន់អង្គរបុរី)។ ប្រាសាទអាស្រមមហាឥសី ជាប្រាសាទតូចមួយដែលសាងឡើងអំពីថ្មពពុះ ឬថ្មបាសាល់ មានរាងបួនជ្រុងស្មើ បែរមុខទៅទិសខាងជើង (រូបទី១)។ ប្រាសាទនេះគេអាចចាត់ទុកជាប្រាសាទដែលសាងឡើងនៅលើភ្នំដំបូងៗគេ ដែលបង្ហាញពីសម័យអន្តរកាលរវាងសម័យហ្វូណននិងចេនឡា ហើយមានអាយុកាលនៅចុងស.វ.ទី៦ ដើមស.វ.ទី៧ ហើយទំនងមានអាយុកាលតំណាលគ្នានឹងគ្រឹះប្រាសាទនៅលើភ្នំដាដែរ[1]។ នៅផ្នែកក្នុងរបស់ប្រាសាទមានកូនបន្ទប់តូចមួយសម្រាប់ការដើរប្រទក្សិណជុំវិញក្នុងកិច្ចពិធីនៃព្រហ្មញ្ញសាសនាដែលគេតែងហៅថា "គភ៌គ្រឹះ"។ សំណង់គភ៌គ្រឹះនៃប្រាសាទភ្នំដាអាចជាប្រាសាទដែលមានសំណង់គភ៌គ្រឹះដំបូងគេនៅក្នុងសិល្បៈខ្មែរ[2]។ នៅលើប្រាសាទមានការលម្អតិចតួចនៅតាមផ្នែកផ្សេងៗដូចជា ហោជាង ផ្តែរ សសរពេជ្រ គុឌុ បង្អួច និងកំពូល។ ផ្តែរទ្វារប្រាសាទនេះពុំបានធ្លាក់ឲ្យចប់សព្វគ្រប់ឡើយ។ ប៉ុន្តែនៅផ្នែកខាងក្រោមយើងឃើញមានរំយោលផ្កាឬកម្រងមាលាដែលមានទម្រង់ជាសិល្បៈដើមរចនាបថសំបូរព្រៃគុក នាចុងស.វ.ទី៦ ដើមស.វ.ទី៧ ដូចធ្លាប់ឃើញនៅថាឡាបរិវ៉ាត់ និងនៅតំបន់សំបូរព្រៃគុកជាដើម (រូបទី២)[3]។ កំពូលប្រាសាទអាស្រមមហាឥសីមានរាងជាផ្កាឈូកក្រពុំដែលមានទម្រង់របៀបសិល្បៈឥណ្ឌា ដែលគេស្គាល់ថា

[1] Parmrntier 1927: 188-144.

[2] គុយ ម៉ីចៀន ២០១៨: ២៣-២៧។

[3] Bénisti 1971: 188-144.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

"Kalasah" និង "Amalaka" (រូបទី៣)។

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩២០ ពេលដែលលោក Henri Parmentier បានមកដល់ប្រាសាទនេះ ហើយបានឃើញផ្នែកខ្លះនៃប្រាសាទបានរលំរួចទៅហើយ[4]។ បន្ទាប់មកទៀតលោក Henri Mauger រៀបចំជួសជុលប្រាសាទនេះឡើងវិញនៅឆ្នាំ១៩៣៥ ដោយប្រើបច្ចេកទេស Anastylosis ពោល គឺការរើថ្មប្រាសាទចេញទាំងអស់ រួចបង់លេខតាមលំដាប់លំដោយរៀបសារជាថ្មី[5]។ អ្នកស្រាវជ្រាវមួយចំនួនយល់ថាប្រាសាទនេះតម្កល់ទេពហរិហរ ដែលមានកម្ពស់ ១៧៣ សង់ទីម៉ែត្រ និងទទឹង៦៥ សង់ទីម៉ែត្រ និងមានកម្រាស់ ២៣ សង់ទីម៉ែត្រ[6]។ សព្វថ្ងៃរូបនេះបានតម្កល់ទុកនៅសារមន្ទីរហ្គីម៉េ (Musée Guimet) នៃប្រទេសបារាំង (រូបទី៤)។ ប៉ុន្តែ ករណីនេះយើងគួរតែយកមកពិចារណាដែរ ព្រោះប្រាសាទនេះមានកូនបន្ទប់តូចមួយនៅខាងក្នុង។ ដូច្នេះហើយ បើគិតតាមកម្ពស់របស់ព្រះហរិហរនោះ ហាក់ដូចជាមិនសមមាត្រគ្នាជាមួយកូនបន្ទប់នោះទាល់តែសោះ។ ព្រះហរិហរនេះអាចជាទេពដែលតម្កល់នៅតាមរូបភ្នំ ឬប្រាសាទឥដ្ឋចាស់ៗដែលសព្វថ្ងៃនៅសល់តែគ្រឹះតែប៉ុណ្ណោះនៅលើភ្នំដា។ ប្រការដែលគួរឱ្យពិចារណាមួយទៀតគឺ ប្រភេទថ្មដែលយកមកសាងសង់ប្រាសាទគឺជាថ្មបាសាល់ ដែលជាថ្មមួយប្រភេទមានភាពរឹងខ្លាំងខុសពីថ្មធម្មតា ហើយថ្មប្រភេទនេះទៀតក៏ពុំមាននៅក្នុងតំបន់ក្បែរៗប្រាសាទនេះដែរ។ ប្រភេទថ្មនេះគេប្រទះឃើញមាននៅវាំងខេត្តកំពង់ចាម និងខេត្តក្រចេះត្រង់មុំថ្មគ្រែតែប៉ុណ្ណោះ[7]។ ប្រាសាទដែលសាងពីថ្មបាសាល់នេះមានតែពីរប៉ុណ្ណោះនៅក្នុងស្រុកខ្មែរគឺ ប្រាសាទអាស្រមមហាឥសី ស្ថិតនៅជើងភ្នំដា ក្នុងខេត្តតាកែវ និងប្រាសាទគុកព្រះធាតុ ស្ថិតនៅចង្កេះភ្នំហាន់ជ័យ ខេត្តកំពង់ចាម (រូបទី៥)។

## ឯកសារយោង

Aymonier, Etienne

1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.

Henri, Mauger

1936, L'Àsram Mahà Rosei. in: *BEFEO*. Tome 36, pp. 65-95.

Parmentier, Henri

1927, *L'Art Khmer Primitif*. Paris: G. Van Oest.

Pirre Baptiste & Thierry Zéphir

[4] Parmentier 1927: 124-127.

[5] Mauger 1936: 65-95.

[6] Baptiste & Zéphir 2008: 53; Aymonier 1900: 200.

[7] Vickery 2003: 19; Mauger 1936: 92-93.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

KHMER CIVILIZATION

2008, *L'art Khmer dans les collections de musée Guimet*, Paris.
Vickery, Michael
2003, Funan Reviewed: Deconstructing the Ancients. *BEFEO*, 90-91: 101-144.



រូបទី១៖ ប្រាសាទអាស្រមមហាឥសី ថតពីជ្រុងខាងជើង



រូបទី២៖ ការលម្អនៅលើផ្តែរទ្វារនិងហោជាង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបទី៣ៈ ផ្នែកកំពូលប្រាសាទអាស្រមមហាឥសី





រូបទី៤-៥ៈ ព្រះហរិហររក្សានៅសារមន្ទីរហ្គីម៉េ ប្រទេសបារាំង និងប្រាសាទគុកព្រះធាតុ ខេត្តកំពង់ចាម

អត្ថបទដោយៈ ម៉ង់ រ៉ាលី